# ថ្នាំបង្ការ
## សម្រាប់កុមារដែលគ្រប់អាយុចូលរៀន



ថ្នាំបង្ការទាំងឡាយគឺជាចំណុចសំខាន់ដើម្បីការពារកុមារប្រឆាំងនឹងជំងឺកម្រិតធ្ងន់ធ្ងរផ្សេងៗ។ នៅក្នុងរដ្ឋ California មុនពេលចាប់ផ្តើមចូលសាលារៀន ឬទីតាំងថែទាំកុមារនោះ កុមារទាំងអស់ត្រូវការឱ្យឪពុកម្តាយរបស់ពួកគេផ្តល់ជូនកំណត់ត្រានៃការចាក់ថ្នាំបង្ការពេញលេញរបស់ពួកគេដល់ទីកន្លែងទាំងនោះ ដោយមិនគិតថាតើពួកគេជាអ្នកចុះឈ្មោះថ្មី ឬជាអ្នកផ្ទេរថ្នាក់នោះទេ។ នៅពេលបានទទួលចាក់ថ្នាំបង្ការពេញលេញ កុមារទាំងឡាយមិនត្រឹមតែការពារខ្លួនពួកគេផ្ទាល់នោះទេ ប៉ុន្តែក៏ធ្វើឱ្យប្រាកដថាសុខភាព និងសុវត្ថិភាពរបស់មិត្តរួមថ្នាក់ និងគ្រូបង្រៀនរបស់ពួកគេបានល្អផងដែរ។



ថ្នាំបង្ការទាំងនេះមានបានប្រើប្រាស់ជាច្រើនទសវត្សរ៍ ហើយមានសុវត្ថិភាពក្នុងការទប់ស្កាត់ជំងឺនាពេលកុមារភាពផ្សេងៗ ដូចជាជំងឺកញ្ជ្រឹល (measles) ជំងឺស្រឡទែន (mumps) និងជំងឺអុតស្វាយ (chickenpox) ហើយអាចបញ្ឈប់ការរីករាលដាលនៃការឆ្លងជំងឺនៅតាមសាលារៀន និងនៅផ្ទះ ផងដែរ។ មានការធ្វើតេស្តយ៉ាងហ្មត់ចត់ ដើម្បីធ្វើឱ្យប្រាកដថាថ្នាំបង្ការទាំងនេះផ្តល់ដល់កូនរបស់អ្នកនូវប្រព័ន្ធការពារច្រើនជាងប្រសិនបើពួកគេមិនបានចាក់ថ្នាំបង្ការនោះ។

សម្រាប់ប្រព័ន្ធការពារខ្ពស់បំផុត កុមារទាំងឡាយគួរតែធ្វើឱ្យថ្នាំបង្ការទាំងអស់របស់ពួកគេនៅតែគ្រប់លក្ខណៈនិងទាន់ពេលវេលា - រួមទាំងថ្នាំបង្ការទាំងឡាយដែលការពារពួកគេប្រឆាំងនឹងជំងឺគ្រុនផ្តាសាយធំ (flu) និងជំងឺ COVID-19 ផងដែរ។

## តើកូនរបស់ខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការណាខ្លះ?

**សម្រាប់កម្រិត TK (កម្រិតមត្តេយ្យដែលអាចផ្ទេរថ្នាក់បាន) ឬកម្រិត K (កម្រិតមត្តេយ្យ) រហូតដល់ថ្នាក់ទី 12៖**

- **ថ្នាំបង្ការ DTaP៖** កុមារដែលមានអាយុក្រោម 7 ឆ្នាំត្រូវការទទួលចាក់ជាច្រើនដូស ដើម្បីការពារប្រឆាំងនឹងជំងឺខាន់ស្លាក់ (diphtheria) ជំងឺតេតាណូស (tetanus) និងជំងឺក្អកមាន់ (pertussis/whooping cough) ដែលមានគ្រោះថ្នាក់ជាពិសេសចំពោះទារក។
- **ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ B (Hepatitis B)៖** នេះគឺជាលំដាប់ថ្នាំបង្ការដែលមានចំនួនពីរ ឬបីដូស ហើយដែលមានការណែនាំសម្រាប់ឱ្យមនុស្សគ្រប់រូបទទួលចាក់ ដើម្បីទប់ស្កាត់ជំងឺមហារីក និងជំងឺផ្នែកថ្លើមដែលបង្កឡើងដោយមេរោគ Hepatitis B។
- **ថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើង (Polio)៖** ថ្នាំបង្ការនេះមានប្រសិទ្ធិភាពសម្រាប់ការពារកុមារប្រឆាំងនឹងជំងឺកម្រិតធ្ងន់ធ្ងរនេះដែលអាចបណ្តាលឱ្យមានការខ្វិនពេញមួយជីវិតបាន។
- **ថ្នាំបង្ការ MMR៖** ត្រូវការទទួលចាក់ថ្នាំបង្ការចំនួនពីរដូសសម្រាប់កម្រិតការពារខ្ពស់បំផុតប្រឆាំងនឹងជំងឺដែលងាយស្រួលនឹងឆ្លងទាំងនេះ៖ កញ្ជ្រឹល (measles) ស្រឡទែន (mumps) និងស្អូច (rubella/German measles)។
- **ថ្នាំបង្ការជំងឺអុតស្វាយ (Chickenpox)៖** នេះគឺជាថ្នាំបង្ការដែលមានលំដាប់ចំនួនពីរដូស ហើយដែលមានផ្តល់ជូនដល់កុមារ ដើម្បីទប់ស្កាត់ជំងឺដែលអាចឆ្លងបានដោយងាយស្រួលនេះ ហើយបណ្តាលឱ្យមានកន្ទួលដែលរមាស់ និងដូចជាពងបែក។
- **ថ្នាំបង្ការជំងឺគ្រុនផ្តាសាយធំ (Flu)៖** អ្នកគួរតែទទួលចាក់ថ្នាំបង្ការនេះជារៀងរាល់ឆ្នាំ ជាពិសេសនៅរដូវស្លឹកឈើជ្រុះ ដើម្បីកាត់បន្ថយហានិភ័យនៃការកើតជំងឺគ្រុនផ្តាសាយធំ។

# ថ្នាំបង្ការ
## សម្រាប់កុមារដែលគ្រប់អាយុចូលរៀន



- **ថ្នាំបង្ការជំងឺ COVID-19៖** យូរៗម្តង មានការធ្វើឱ្យថ្នាំបង្ការនេះបានថ្មីឡើងវិញ ដើម្បីការពារប្រឆាំងនឹងពូជថ្មីបំផុតរបស់មេរោគ។ មានការណែនាំឱ្យមនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ ទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated COVID-19 vaccine) យ៉ាងហោចណាស់ចំនួន 1 ដូស។
- **ថ្នាំបង្ការ Tdap៖** កុមារធំៗត្រូវការទទួលចាក់ចំនួនមួយដូស ដើម្បីការពារប្រឆាំងនឹងជំងឺតេតាណូស (tetanus) ជំងឺខាន់ស្លាក់ (diphtheria) និងជំងឺក្អកមាន់ (pertussis/whooping cough)។ មានការតម្រូវចាំបាច់ឱ្យសិស្សទាំងឡាយដែលនឹងចូលទៅថ្នាក់ទី 7 ទទួលចាក់ថ្នាំបង្ការនេះ។ (សូមកត់សម្គាល់ថាថ្នាំបង្ការនេះគឺខុសគ្នាពីថ្នាំបង្ការ DTaP។)

សូមសាកសួរទៅកាន់តំបន់សាលារៀន (school district) របស់អ្នក ដើម្បីបញ្ជាក់ថាមានការតម្រូវចាំបាច់ឱ្យទទួលចាក់ថ្នាំបង្ការណាខ្លះសម្រាប់ចូលសាលារៀន។ សម្រាប់បញ្ជីឈ្មោះថ្នាំបង្ការទាំងអស់ទៅតាមអាយុ និងតម្រូវការសម្រាប់កម្រិត TK ឬកម្រិត K រហូតដល់ថ្នាក់ទី 12 នោះ សូមចូលទៅកាន់គេហទំព័រ shotsforschool.org។

**ពិភាក្សាជាមួយនឹងអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកអំពីវិធីការពារទារក និងកុមារតូចៗពីជំងឺតាមផ្លូវដង្ហើមកម្រិតធ្ងន់ធ្ងរដោយសារ RSV។**

## តើខ្ញុំទទួលចាក់ថ្នាំបង្ការបានយ៉ាងដូចម្តេចខ្លះ?

- ពិភាក្សាជាមួយនឹងគ្រូពេទ្យជំនាញខាងកុមាររបស់អ្នកពីថ្នាំបង្ការទាំងឡាយសម្រាប់ពេលវិលត្រឡប់ទៅសាលារៀនវិញ និងសម្រាប់ប្រចាំឆ្នាំ។
- ប្រសិនបើអ្នកមិនមានអ្នកផ្តល់សេវាកម្មថែទាំសុខភាពប្រចាំខ្លួនទេនោះ សូមចូលទៅកាន់គេហទំព័រ http://publichealth.lacounty.gov/vaccines សម្រាប់បញ្ជីឈ្មោះគ្លីនិកដែលផ្តល់ការចាក់ថ្នាំបង្ការជូនដោយមិនគិតថ្លៃ ឬគិតថ្លៃទាប ហើយនិងព័ត៌មានបន្ថែមទៀតអំពីថ្នាំបង្ការទាំងឡាយ។
- ចំណុចល្អបំផុតនោះគឺថាអ្នកអាចទទួលចាក់ថ្នាំបង្ការភាគច្រើនក្នុងពេលតំណាលគ្នាបាន! នេះមានន័យថាកូនរបស់អ្នកមានភាពមិនស្រួលក្នុងខ្លួនតិចជាងមុន ហើយអ្នកនឹងមិនចំណាយពេលវេលាច្រើនដោយមិនបានធ្វើសកម្មភាពផ្សេងទៀតរបស់អ្នក ផងដែរ។



### មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health Call Center)

សម្រាប់ព័ត៌មានបន្ថែម មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈមានបម្រើសេវាកម្មជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈលេខ **1-833-540-0473**។